# និយ័តករគណនេយ្យនិងសវនកម្ម

## ព្រឹត្តិបត្រព័ត៌មានប្រចាំខែឧសភា ឆ្នាំ២០២៤

លេខ:០០៥


សេចក្តីសង្ខេបព័ត៌មាន និងព្រឹត្តិការណ៍សំខាន់ៗប្រចាំខែឧសភារបស់**និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** រួមមានដូចខាងក្រោម៖

## ពិធីប្រកាសដាក់ឱ្យអនុវត្តគម្រោង FMIS ទៅកាន់ការដ្ឋានបន្ថែមថ្មី និងប្រើប្រាស់សមិទ្ធផល ថ្មីៗជាផ្លូវការ"



១.កាលព្រឹកថ្ងៃពុធ ១ កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៤ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក ទឹម សត្យា** អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ បានអញ្ជើញចូលរួមកម្មវិធីបើកពិធីប្រកាសដាក់ឱ្យអនុវត្តគម្រោង FMIS ទៅកាន់ការដ្ឋានបន្ថែមថ្មី និងប្រើប្រាស់សមិទ្ធផលថ្មីៗជាផ្លូវការ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** នៅសណ្ឋាគារសុខាភ្នំពេញ។

## កិច្ចប្រជុំក្រុមការងារបច្ចេកទេសទី១ នៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (FSDS) ឆ្នាំ ២០២១- ២០៣០



## ព័ត៌មានថ្មីៗ


ពិធីប្រកាសដាក់ឱ្យអនុវត្តគម្រោងFMIS សូមអាននៅទំព័រ..........១

កិច្ចប្រជុំក្រុមការងារបច្ចេកទេសទី១ សូមអាននៅទំព័រ..........២

កិច្ចប្រជុំបច្ចេកទេសបន្តលើ"សេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងគុណភាពសវនកម្ម និងការអះអាង សូមអាននៅទំព័រ..........២

កិច្ចពិភាក្សាផ្ទៃក្នុងក្រោមក្របខណ្ឌន.គ.ស. សូមអាននៅទំព័រ..........៣

កិច្ចប្រជុំគណៈកម្មការរៀបចំការប្រឡងប្រជែងមន្ត្រីលក្ខន្តិកៈ សូមអាននៅទំព័រ..........៣

វគ្គបណ្តុះបណ្តាលស្តីពី ការអនុវត្តការងារសវនកម្ម សូមអាននៅទំព័រ..........៤

កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ សូមអាននៅទំព័រ..........៤

កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសូមអាននៅទំព័រ..........៥

កិច្ចប្រជុំដំបូងរបស់ក្រុមការងាររៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេក-វិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ សូមអាននៅទំព័រ..........៥

ការប្រឡងប្រជែងជ្រើសរើសមន្ត្រីលក្ខន្តិកៈ សូមអាននៅទំព័រ..........៦


© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ សូមអាននៅទំព័រ......................................៦

វគ្គបណ្តុះបណ្តាល សូមអាននៅទំព័រ.........៦

ជំនួបជាមួយជំនាញការធនាគារពិភពលោក សូមអាននៅទំព័រ......................................៧

កិច្ចប្រជុំពិភាក្សាជាមួយវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជានឹងស្ថាប័នACCA សូមអាននៅទំព័រ.............៧

វគ្គបណ្តុះបណ្តាល សូមអាននៅទំព័រ.........៨

វគ្គបណ្តុះបណ្តាល សូមអាននៅទំព័រ.........៨

វគ្គបណ្តុះបណ្តាល សូមអាននៅទំព័រ.........៩

កិច្ចប្រជុំបច្ចេកទេសអង្គភាពក្រោមឱវាទ អ.ស.ហ. សូមអាននៅទំព័រ..................១០

កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ សូមអាននៅទំព័រ...................................១១

២.កាលពីថ្ងៃចន្ទ ១៣រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៤ នៅសាលប្រជុំនៃ អ.ស.ហ. **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី ថោ សេដ្ឋចាន់លីដា** អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ បានចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសទី១ នៃគណៈ-កម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យហិរញ្ញវត្ថុ (FSDS) ឆ្នាំ២០២១- ២០៣០ ក្រោមអធិបតីភាព **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. និងមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី ជាអនុប្រធាន និងសមាជិក ក្រុមការងារបច្ចេកទេសទី១ នៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។ គោលបំណងនៃកិច្ចប្រជុំនេះដើម្បីពិនិត្យសេចក្តីព្រាង (FSDA) ឆ្នាំ២០២១- ២០៣០ ឱ្យបានគ្រប់ជ្រុងជ្រោយ។

# កិច្ចប្រជុំបច្ចេកទេសលើ “សេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងគុណភាព សវនកម្មនិងការអះអាង”




៣.កាលពីថ្ងៃសុក្រ ១០ រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំកិច្ចប្រជុំបច្ចេកទេសបន្តលើ “សេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងគុណភាព សវនកម្ម និងការអះអាង” ជាមួយក្រុមហ៊ុន Big4 និងវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (វ.គ.ស.ក.) ដឹកនាំដោយ **លោក ជេន ផាត** អគ្គនាយករង នៃ ន.គ.ស. តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ នៃ ន.គ.ស. តាមប្រព័ន្ធអនឡាញ (Zoom)។ កិច្ចប្រជុំនេះមានគោលបំណងប្រមូលធាតុចូលគន្លឹះ និងគ្រោងដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈនាពេលខាងមុខ។

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

# កិច្ចពិភាក្សាផ្ទៃក្នុងក្រោមក្របខណ្ឌ ន.គ.ស.




៤.កាលពីថ្ងៃអង្គារ ១៤រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៤ នៅបន្ទប់ប្រជុំធំ ន.គ.ស. **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង និងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម បានដឹកនាំកិច្ចពិភាក្សាក្រោមរបៀបវារៈដូចខាងក្រោម៖

១. សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការថ្នាក់ជាតិស្តីពីការរាយការណ៍ព័ត៌មានចីរភាព

២. សេចក្តីព្រាងប្រកាសស្តីពីការបង្កើតគណៈកម្មការបច្ចេកទេសស្តង់ដាគណនេយ្យសម្រាប់វិស័យសាធារណៈ។

# កិច្ចប្រជុំគណៈកម្មការរៀបចំការប្រឡងប្រជែងមន្ត្រីលក្ខន្តិកៈ




៥.កាលពីថ្ងៃអង្គារ ១៥ រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំកិច្ចប្រជុំគណៈកម្មការរៀបចំការប្រឡងប្រជែងមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បម្រើការងារនៅនិយ័តករគណនេយ្យនិងសវនកម្ម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** និងជាប្រធាន គណៈកម្មការរៀបចំការប្រឡង អមដោយ **ឯកឧត្តម គុយ សាវុធ** អគ្គលេខាធិការរង ជាអនុប្រធាន លោក លោកស្រី អគ្គនាយករង អនុប្រធាននាយកដ្ឋាន និងប្រធាន-អនុប្រធានការិយាល័យជាសមាជិក តាមរយៈប្រព័ន្ធអនឡាញ។

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

# វគ្គបណ្តុះបណ្តាលស្តីពី ការអនុវត្តការងារសវនកម្ម




៦.កាលពីថ្ងៃព្រហស្បតិ៍ ២កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ **លោក ជេន ផាត** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម បានអញ្ជើញជាអធិបតីភាពក្នុងការបើកវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តការងារសវនកម្ម។ ន.គ.ស. បាន សហការជាមួយក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការអនុវត្តការងារសវនកម្ម ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ នៃការិយាល័យត្រួតពិនិត្យ។ វគ្គបណ្តុះបណ្តាលនេះមានរយៈពេល២ ថ្ងៃគឺ ចាប់ពីថ្ងៃទី៩-១០ ខែឧសភា ឆ្នាំ២០២៤ ដោយមានគោលដៅផ្តល់ជាធាតុចូលបន្ថែមតាមរយៈការអនុវត្តការងារសវនកម្មជាក់ស្តែងក្នុងនាមជាសវនករ។

# កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈស្តីពី “ការទទួលយកស្តង់ដាសវនកម្មអន្តរជាតិសម្រាប់សហគ្រាសមិនស្មុគស្មាញ (The Adoption of ISA for LCE In Cambodia)”



៧.កាលពីថ្ងៃសុក្រ ៣កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦ ត្រូវនឹងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ នៅអគារ ៣៤៥ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ ស្តីពី“ការទទួលយកស្តង់ដាសវនកម្មអន្តរជាតិសម្រាប់សហគ្រាសមិនស្មុគស្មាញ (The Adoption of ISA for LCE In Cambodia)” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក ជេន ផាត** អគ្គនាយករង ព្រមទាំងមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសនៃ ន.គ.ស.។ កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ នេះមានការអញ្ជើញចូលរួមពីតំណាងមកពីវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា និយ័តករក្រោមឱវាទ អ.ស.ហ. ធនាគារជាតិនៃកម្ពុជាស្ថាប័នពាក់ព័ន្ធ

និងក្រុមហ៊ុនគណនេយ្យនិងសវនកម្ម សរុបប្រមាណ65 នាក់។ កិច្ចប្រជុំពិគ្រោះយោបល់នេះរៀបចំឡើងក្នុងគោលបំណងប្រមូលធាតុចូលសំខាន់ៗដែលជាមូលដ្ឋានសម្រាប់ពិចារណាក្នុងការរៀបចំសេចក្តីព្រាងប្រកាសដាក់អោយអនុវត្តក្នុងប្រទេសកម្ពុជា។

## កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ



៨.កាលពីរថ្ងៃចន្ទ ៦ កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែសភា ឆ្នាំ២០២៤ នៅ ធនាគារជាតិនៃកម្ពុជា **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករ គណនេយ្យនិងសវនកម្ម អមដោយ**លោកស្រី ថោ សេដ្ឋចាន់លីដា** អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ បានអញ្ជើញចូលរួម កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុដើម្បីពិភាក្សាលើសេចក្តីព្រាងចុងក្រោយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០២១-២០៣០ ក្រោមអធិបតីភាពរបស់ **លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល** នៃធនាគារជាតិនៃកម្ពុជា ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាអនុប្រធាន និងសមាជិកនៃ គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ។

## កិច្ចប្រជុំដំបូងរបស់ក្រុមការងាររៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រ អភិវឌ្ឍន៍បច្ចេកវិទ្យា ហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ



៩.កាលពីថ្ងៃព្រហស្បតិ៍ ៩ កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ នៅទីស្តីការ អ.ស.ហ. **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាអនុប្រធានក្រុមការងាររៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រ

អភិវឌ្ឍន៍បច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង ព្រមទាំងមន្ត្រីជំនាញចំនួន៣រូប បានអញ្ជើញចូលរួមកិច្ចប្រជុំដំបូងរបស់ក្រុមការងាររៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. និងជាប្រធានក្រុមការងារ ។

## ការប្រឡងប្រជែងជ្រើសរើសមន្ត្រីលក្ខន្តិកៈ



១០.កាលពីថ្ងៃសៅរ៍ ១១កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីលក្ខន្តិកៈចំនួន១៥រូបឱ្យចូលបម្រើការងារនៅ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាប្រធានគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសបេក្ខជនជាមន្ត្រីលក្ខន្តិកៈ អមដោយ **ឯកឧត្តម គុយ សារុធ អគ្គលេខាធិការរង** នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធរនាគារ និងជាអនុប្រធានគណៈកម្មការ និងលោក លោកស្រី ជាសមាជិក នៃគណៈកម្មការរៀបចំការប្រឡង ប្រជែងជ្រើសរើសបេក្ខជនមន្ត្រីលក្ខន្តិកៈ។

## កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈជាមួយតំណាងក្រុមហ៊ុនគណនេយ្យនិងសវនកម្ម



១១.កាលពីថ្ងៃចន្ទ ១៣ កើត ខែពិសាខ ឆ្នាំ រោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ នៅ អគារការិយាល័យ ៣៤៥ ភ្នំពេញ, **លោក ជេន ផាត** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនាយកដ្ឋាន គ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម និងនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព បានដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈជាមួយតំណាងក្រុមហ៊ុនគណនេយ្យនិងសវនកម្ម និងមកពីស្ថាប័នពាក់ព័ន្ធ ដូចជាតំណាងមកពីធនាគារជាតិ, តំណាងមកពីនិយ័តករមូលបត្រ, និយ័តករបរធនបាលកិច្ច, និយ័តករធានារ៉ាប់រង, តំណាងមកពីអគ្គលេខាធិការដ្ឋាន អ.ស.ហ. និងដៃគូអភិវឌ្ឍន៍លើ "សេចក្តីព្រាងប្រកាសស្តីពីការត្រួតពិនិត្យគុណភាពសវនកម្មនិងការអះអាង"។ ក្នុងគោលបំណងដើម្បីបើកវេទិកាពិភាក្សាជាមួយភាគីពាក់ព័ន្ធក្នុងគោលបំណងប្រមូលធាតុចូលបន្ថែម និងទទួលយកសំណូមពរបន្ថែមដើម្បីធានាឱ្យសេចក្តីព្រាងប្រកាសកាន់តែមានភាពគ្រប់ជ្រុងជ្រោយ អាចអនុវត្តបាន មានសង្គតិភាព និងឆ្លើយតបនឹងសេចក្តីត្រូវការវិនិយោគមុននឹងដាក់បន្តទៅកិច្ចពិភាក្សាជាមួយ អ.ស.ហ.។

## វគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យគុណភាពសវនកម្ម



១២.ទីក្រុងកូឡាឡាំពួរ៖ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ជេន ផាត** អគ្គនាយករង បានដឹកនាំថ្នាក់ដឹកនាំនាយកដ្ឋានប្រធានការិយាល័យ និងមន្ត្រីជំនាញនៃនាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យគុណភាពសវនកម្ម, ទស្សនកិច្ចទីស្នាក់ការរបស់សមាគមគណនេយ្យករជំនាញជាន់ខ្ពស់ម៉ាឡេស៊ី (ACCA Malaysia) និងក្រុមហ៊ុន PWC Malaysia នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ចំនួន៣ថ្ងៃ ចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៤ ក្នុងគោលបំណងស្វែងយល់បន្ថែមលើការត្រួតពិនិត្យគុណភាពសវនកម្ម ក្នុងនាមជានិយ័តករ។

## ជំនួបជាមួយជំនាញការធនាគារពិភពលោក



© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

១៣.កាលពីថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ នៅបន្ទប់ប្រជុំ ន.គ.ស. **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពង់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយមន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេសបានទទួលជួបជាមួយជំនាញការធនាគារពិភពលោកដើម្បីពិនិត្យនិងពិភាក្សាទៅលើ៖ ១) វឌ្ឍនភាពនៃការអនុវត្តការរាយការណ៍ចីរភាពនៅកម្ពុជានិង ២)បេសកកម្មរបស់ធនាគារពិភពលោកទៅកាន់ស្ថាប័នពាក់ព័ន្ធ។

## កិច្ចប្រជុំពិភាក្សាជាមួយវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជានឹងស្ថាប័នACCA




១៤.កាលពីថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម បានចូលរួមកិច្ចប្រជុំពិភាក្សា ជាមួយ វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជានឹងស្ថាប័ន ACCA ស្តីពីលក្ខខណ្ឌតម្រូវដើម្បីក្លាយជាសមាជិកពេញសិទ្ធរបស់សហព័ន្ធគណនេយ្យករអន្តរជាតិតាមប្រព័ន្ធអនឡាញ (Microsoft Teams)។

## វគ្គបណ្តុះបណ្តាលស្តីពី “ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម”



១៥.កាលពីថ្ងៃព្រហស្បតិ៍ ១រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤ **និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី **"ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម"** រយៈពេល៦ថ្ងៃ នៅអគារ ៣៤៥។ វគ្គបណ្ដុះបណ្ដាលនេះប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម។ វគ្គបណ្ដុះបណ្ដាលនេះក៏មានការអញ្ជើញចូលរួមពី **លោក សាយ សុខខេង** អគ្គនាយកក្រុមហ៊ុនឌីអេស្វស៊ី (DFC) ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រី នៃនិយ័តករគណនេយ្យនិងសវនកម្ម ក្នុងនោះសម្រាប់វគ្គនេះក៏មានការចុះឈ្មោះចូលរួមពីសំណាក់ក្រុមហ៊ុន សហគ្រាស និងបុគ្គលជាប់ កាតព្វកិច្ចទទួលខុសត្រូវលើកិច្ចការគណនេយ្យសរុបចំនួន ៥២នាក់។ វគ្គបណ្ដុះបណ្ដាលនេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹង និងសិក្សាលម្អិតលើបច្ចុប្បន្នភាពលក្ខខណ្ឌតម្រូវនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យមដែលជាមូលដ្ឋានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងសម្រាប់ការចូលរួមអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម ដូចមានចែងក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្មនិងបទប្បញ្ញត្តិពាក់ព័ន្ធ។

## វគ្គបណ្ដុះបណ្ដាលស្ដីពី មូលដ្ឋានគ្រឹះគណនេយ្យមុននឹងសិក្សាស្តង់ដាគណេនេយ្យ



១៦.កាលពីថ្ងៃចន្ទ៥រោចខែពិសាខឆ្នាំរោង ឆស័ក ព.ស.២៥៦៨ត្រូវនឹងថ្ងៃទី២៧ខែឧសភាឆ្នាំ២០២៤ **និយ័តករ គណនេយ្យ និងសវនកម្មនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី **មូលដ្ឋានគ្រឹះគណនេយ្យមុននឹងសិក្សាស្តង់ដាគណេនេយ្យ** មានរយៈពេល៣ថ្ងៃ។ វគ្គបណ្ដុះបណ្ដាលនេះប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី នាង បូនី** អគ្គនាយករង **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និង មន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម ម្ចាស់សហគ្រាស និងអ្នកដែលមានការទទួលខុសត្រូវលើកិច្ចការគណនេយ្យនិងហិរញ្ញវត្ថុចំនួន៤០នាក់។ វគ្គបណ្ដុះបណ្ដាលនេះត្រូវបានរៀបចំឡើងនៅក្នុងគោលដៅ ដើម្បីបញ្ជ្រាបការយល់ដឹងអំពីមូលដ្ឋានក្នុង ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្តោតទៅលើផ្នែកសំខាន់ៗដែលមូលដ្ឋានមុននឹងឈានទៅសិក្សាវគ្គស៊ីជម្រៅគឺវគ្គស្តង់ដា របាយការណ៍ទាក់ទងនិងហិរញ្ញវត្ថុអន្តរជាតិកម្ពុជា សម្រាប់សហគ្រាសធុននិងមធ្យម (CIFRS For SMEs) និងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរកម្ពុជា(CIFRS)។

## វគ្គបណ្ដុះបណ្ដាលលម្អិតស្ដីពីស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈមូលដ្ឋានបង្គរ

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម




១៧.ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ហេង សំណាង** ប្រធានការិយាល័យស្តង់ដាគណនេយ្យសាធារណៈ និង **លោកស្រី អេង រ័ត្នឆដា** មន្ត្រីជំនាញ នៃការិយាល័យស្តង់ដាគណនេយ្យសាធារណៈ រួមជាមួយតំណាងអគ្គនាយកដ្ឋានរតនាគារជាតិ **លោក ជា សុជាតិ** ប្រធាននាយកដ្ឋានគោលការណ៍គណនេយ្យនិងវិភាគការអនុវត្តថវិកា និង **លោក ម៉ៅ ទី** មន្ត្រីជំនាញ នៃអគ្គនាយកដ្ឋានរតនាគារជាតិបានចូលរួមវគ្គបណ្តុះបណ្តាលលម្អិតស្តីពីស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈមូលដ្ឋានបង្គរ ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២០-២៤ ខែឧសភា ឆ្នាំ២០២៤ នៅទីក្រុងឡុងដ៏ ចក្រភពអង់គ្លេស។

## កិច្ចប្រជុំបច្ចេកទេស នៃអង្គភាពក្រោមឱវាទ អ.ស.ហ.




១៨.កាលពីថ្ងៃព្រហស្បតិ៍ ៨រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស **លោកស្រី តាំង ឈីវហុង** ប្រធានការិយាល័យ នីតិកម្មនិងដោះស្រាយវិវាទ និង **លោក ពេជ សុភាចារ** មន្ត្រីជំនាញនាយកដ្ឋានបច្ចេកទេស បានចូលរួមកិច្ចប្រជុំបច្ចេកទេស នៃអង្គភាពក្រោមឱវាទ អ.ស.ហ. ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម មុី វ៉ាន់ រដ្ឋលេខាធិការ** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. ដើម្បីពិនិត្យនិងផ្តល់យោបល់ទៅលើ ១) សេចក្តីព្រាងច្បាប់ស្តីពីអាជីវកម្មនិងសេវាកម្មអចលនវត្ថុ និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ និង២) “សន្ទានុក្រមគណនេយ្យនិងសវនកម្មក្នុងក្របខណ្ឌស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម” តាមប្រព័ន្ធអនឡាញ (Zoom)។

## កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈស្តីពី “ការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាមញ្ញកម្ពុជា”



១៩.កាលពីថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈស្តីពី “ការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាមញ្ញកម្ពុជា” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** និយ័តករគណនេយ្យនិងសវនកម្ម នៅសណ្ឋាគារភ្នំពេញ។ សិក្ខាសាលានេះក៏មានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ទាំងអស់ដែលជាតំណាងមកពីក្រសួង-ស្ថាប័នរដ្ឋ និងឯកជនរួមមាន អគ្គនាយកដ្ឋានពន្ធដារ, សភាពាណិជ្ជកម្មកម្ពុជា, សមាគមធនាគារនៅកម្ពុជា, សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា, ធនាគារពិភពលោក, ធនាគារ សហគ្រាសធុនតូចនិងមធ្យម, ក្រុមហ៊ុនគណនេយ្យនិងសវនកម្ម ព្រមទាំងសាធារណជនទូទៅផងដែរ។ កិច្ចប្រជុំពិគ្រោះយោបល់ នេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីពិនិត្យលទ្ធភាព និងភាពចាំបាច់ក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាមញ្ញកម្ពុជាដែលជាស្តង់ដាមួយបានយកមកគិតគូរតាំងពីឆ្នាំ២០២២ សម្រាប់បរិបទសេដ្ឋកិច្ចកម្ពុជាមុននឹងឈានទៅការអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិ។

រៀបចំដោយ÷**លោក ឡាយវិ ចិត្រ**

សម្របសម្រួលអត្ថបទ÷**កញ្ញា សុខ ណាវី**